# មេរៀនទី ៦៥៖ ព្រះយេស៊ូវប្រោសមនុស្សខ្វាក់ឲ្យជា

## ម៉ាកុស ១០៖៤៦-៥២

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ **https://youtu.be/eEteKPqoN5Q**

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** **https://youtu.be/Ta6_ZdiqPqM**

**គោលបំណង៖** យើងមានសេចក្តីជំនឿលើព្រះយេស៊ូវ។

**ខគម្ពីរចងចាំ៖**
**កិច្ចការ៖ ៣៨** *"គឺពីព្រះយេស៊ូវ ពីស្រុកណាសារ៉ែត ដែលព្រះបានចាក់ព្រះវិញ្ញាណបរិសុទ្ធ និងព្រះ ចេស្តាឲ្យមកសណ្ឋិតលើទ្រង់ ហើយទ្រង់បានយាងចុះឡើងធ្វើការល្អ ព្រមទាំងប្រោសឲ្យអស់អ្នកដែលត្រូវអារក្ស សង្កត់សង្កិនបានជាផង ដ្បិតព្រះបានគង់ជាមួយនឹងទ្រង់"។*

**ចំរៀង** ( *យូធូបលីង* )៖
១.មានទន្លេជីវិត https://youtu.be/AP6fwLxUqK0
២.ព្រះយេស៊ូវមករកមនុស្សមានបាប https://youtu.be/KuGfv2U0YmE
៣.ខ្ញុំនឹងទុកចិត្តទ្រង់ https://youtu.be/WCZlwlstAzc

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត « ដឹកដៃមនុស្សខ្វាក់ »

សម្ភារៈដែលត្រូវការ៖ក្រណាត់សម្រាប់រុំភ្នែក របស់របរដើម្បីបង្កើតជាឧបសគ្គ(កៅអី ដុំថ្ម ដបទឹក ។ល។)



១. ចែកកុមារជា ២ឬ ៤ក្រុម អាស្រ័យលើចំនួនកុមារ

២. ជ្រើសរើសកុមារ ២នាក់ ដើម្បីធ្វើជាតំណាងក្រុមនីមួយៗ។ ម្នាក់ត្រូវដើរតួជាកុមារពិការហើយគេត្រូវបិទភ្នែក និងម្នាក់ទៀតដើរតួជាអ្នកនាំផ្លូវ ។



៣. គ្រូត្រូវដាក់ឧបសគ្គនៅក្នុងថ្នាក់រៀន (កៅអី ដុំថ្ម និងដបទឹក ។ល។)

៤. កុមារដែលជាអ្នកនាំផ្លូវកុមារពិការភ្នែកឆ្លងកាត់ឧបសគ្គពីផ្នែកម្ខាងនៃថ្នាក់រៀន ដោយក្រុមទាំងពីរត្រូវចាប់ផ្តើមពីទិសដៅផ្ទុយគ្នា។

៥. កុមារដែលជាអ្នកនាំផ្លូវត្រូវប្រាប់កុមារដែលត្រូវគេបិតភ្នែកនោះ ឲ្យដើរជាន់លើជើងកុមារ ដែលត្រូវគេបិតភ្នែករបស់ក្រុមម្ខាងទៀត។ ហើយប្រសិនបើកុមារបិទភ្នែកណាដែលជាន់លើជើងបានមុន ក្រុមនោះជាអ្នកឈ្នះ។

## ៤. ការណែនាំមេរៀន

**សកម្មភាព៖** គ្រូកុមារនាំកុមារដើរនៅក្នុងថ្នាក់រៀនរបស់ពួកគេ ដោយឲ្យកុមារទាំងអស់បិទភ្នែកហើយគ្រូស្រែកឲ្យកុមារដើរទៅឆ្វេងស្តាំទៅមុខទៅក្រោយ ។ បន្ទាប់ពីធ្វើសកម្មភាពនេះរួច ឲ្យកុមាទាំងអស់បើកភ្នែក

វិញរួចអង្គុយចុះ ហើយសួរពួកគេថា។

តើប្អូនពិបាកដើរដែរឬទេនៅពេលយើងពិការភ្នែកបែបនេះ? វាជាការពិបាកណាស់ ក្នុងការរស់ដោយយើងមិនអាចមើលអ្វីឃើញនោះ។ ថ្ងៃនេះយើងនឹងរៀនអំពីបុរសពិការភ្នែកម្នាក់ដែលគាត់បានពិការភ្នែក បន្ទាប់ពីគាត់បានកើតរួចហើយ។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃមួយខណៈពេលដែលព្រះយេស៊ូវនិងពួកសិស្សរបស់ទ្រង់បានដើរឆ្លងកាត់បុរសម្នាក់ដែលមានឈ្មោះថា បារទីមេ។ បារទីមេគឺកំពុងតែអង្គុយនៅតាមផ្លូវ ដើម្បីសុំទានដោយសារតែគាត់មិនអាចមើលអ្វីឃើញនោះទេ។ នៅពេលដែលគាត់បានដឹងថា ព្រះយេស៊ូវយាងកាត់ទីនោះ គាត់ក៏ស្រែកឡើងថា "សូមអាណិតមេត្តា ទូលបង្គំផង!" មនុស្សម្នាដែលនៅជិតគាត់បានប្រាប់ឲ្យគាត់ស្ងាត់ទៅ ប៉ុន្តែគាត់មិនបានឈប់នោះទេ។ នៅពេលដែលព្រះយេស៊ូវបានឮ ទ្រង់ក៏បានឈប់ហើយហៅបារទីមេឲ្យមកជិតព្រះអង្គ។

ព្រះយេស៊ូវបានសួរគាត់ថា តើចង់ឲ្យខ្ញុំធ្វើអ្វីដល់អ្នក បារទីមេក៏បានឆ្លើយថា "លោកគ្រូអើយ សូមឲ្យខ្ញុំបានមើលឃើញម្តងទៀត" ។ យើងអាចដឹងថាគាត់ធ្លាប់មើលឃើញពីមុន ដោយព្រោះគាត់បាននិយាយថា "សូមឲ្យខ្ញុំបានមើលឃើញម្តងទៀត" ។ នៅពេលដែលព្រះយេស៊ូវបានឮដូច្នេះទ្រង់តបថា "ទៅចុះ សេចក្តីជំនឿអ្នកបានសង្គ្រោះអ្នកហើយ" ហើយរំពេចនោះបារទីមេក៏បានមើលឃើញវិញ។

ព្រះយេស៊ូវមិនបានសួរគាត់ថា តើអ្នកមានដើរតាមបទបញ្ញត្តិទាំង ១០ ប្រការឬអត់នោះទេ។ ទ្រង់មិនបានឲ្យគាត់ទំលាក់គ្រប់ទាំងអស់នោះទេ។ ហើយទ្រង់ក៏មិនបានឲ្យគាត់ ធ្វើការសន្យាក្នុងការជួយអ្នកដ៏ទៃ ត្រូវទៅព្រះវិហារ ឬក៏ប្រាប់អ្នកដ៏ទៃអំពីព្រះវបិតាឬក៏ព្រះយេស៊ូវនោះដែរ។

ហើយបារទីមេក៏មិនបានធ្វើកិច្ចការទាំងអស់នោះដែរ តែព្រះយេស៊ូវបានប្រោសគាត់ឲ្យជា។ តើអ្នកដឹងថាមូលហេតុអ្វីដែរឬទេ? ពីព្រោះព្រះអង្គមិនបានសុំឲ្យយើងមកទទួលព្រះគុណរបស់ទ្រង់នោះទេ។ យើងមិនសមទទួលបានព្រះគុណនោះទេ ប៉ុន្តែយ៉ាងណាក៏ដោយព្រះចង់ឲ្យវាមកយើង។ ដូច្នេះជំនួសឲ្យការដែលយើងទទួលបានព្រះគុណនោះ ព្រះអង្គចង់ឲ្យយើងមានសេចក្តីជំនឿ និងទូលសូមព្រះគុណពីព្រះ។

ដើម្បីទៅឯនគរស្ថានសួគ៌បាន អ្នកត្រូវតែទទួលបាននូវសេចក្តីសង្គ្រោះជាមុនសិន។ ប៉ុន្តែ តើអ្នកអាចទិញសេចក្តីសង្គ្រោះបានដែរឬទេ? ទេ អ្នកមិនអាចទេ។ គ្រប់ការទាំងអស់ដែលព្រះចង់ឲ្យយើងធ្វើគឺ មានសេចក្តីជំនឿនិងទូលសុំពីព្រះ។ នេះគឺជាអ្វីដែលយើងត្រូវធ្វើ។ យើងមិនអាចទិញវានោះទេ ប៉ុន្តែព្រះអង្គនឹងប្រទានឲ្យដល់យើងនៅពេលដែលយើងចេះទូលសុំ សូមមានជំនឿថាទ្រង់នឹងប្រទានវាឲ្យដល់យើង។

ព្រះជាម្ចាស់តែងតែចង់ឲ្យយើងធ្វើនូវអ្វីដែលល្អបំផុត។ ហើយទ្រង់នៅតែចង់ឲ្យយើងដើរតាមបញ្ញត្តិទាំង ១០ប្រការ ទៅព្រះវិហារ ប្រាប់អ្នកដទៃអំពីព្រះយេស៊ូវ យើងត្រូវការមានសេចក្តីជំនឿ ហើយទូលសុំព្រះឲ្យជួយសង្គ្រោះដល់យើង ចូរជឿថាទ្រង់នឹងធ្វើវា ហើយត្រូវព្យាយាមឱ្យអស់ពីសមត្ថភាពរបស់យើងចំពោះអ្វីៗផ្សេងទៀត។

## ៦. សំនួរពិភាក្សា

១. តើបុរសពិការភ្នែកនោះមានឈ្មោះអ្វី? *(បារទីមេ)*

២. តើគាត់កំពុងធ្វើអ្វីនៅពេលដែលព្រះយេស៊ូវបានធ្វើដំណើរឆ្លងកាត់ទីនោះ? *(សុំទាន)*

៣. តើបារទីមេបានធ្វើអ្វីមួយដើម្បីឲ្យគាត់សាកសមនឹងទទួលបានការប្រោសឲ្យជាដែរឬទេ? *(ទេ)*

៤. តើយើងសមនឹងទទួលបានការសង្គ្រោះ និងឡើងទៅឯនគរស្ថានសួគ៌ដែរឬទេ? *(ទេ)*

៥. តើយើងត្រូវធ្វើដូចម្តេចដើម្បីទទួលបានការសង្គ្រោះ? *(តាមរយៈសេចក្តីជំនឿលើព្រះដែលបានបញ្ជូនព្រះយេស៊ូវមកសុគតលើឈើឆ្កាងដើម្បីអំពើបាបរបស់យើង)*

**៧. ល្បែងកំសាន្ត** **«មនុស្សពិការភ្នែកគូសរូប»**

សម្ភារៈដែលត្រូវការ៖ ក្រដាស និងប៊ិក



១. ចែកកុមារជាពីរក្រុម

២. សូមឲ្យក្រុមនីមួយៗរើសកុមារម្នាក់តំណាងឲ្យសមាជិកក្រុមរបស់ពួកគេ។

៣. រុំភ្នែករបស់កុមារទាំងពីរនាក់។

៤.ឲ្យក្រដាសនិងប៊ិកទៅកុមារទាំងពីរនាក់នោះ ហើយប្រាប់ពួកគេឲ្យគូររូបអ្វីមួយ (ឧទាហរណ៍៖ ផ្លែប៉ោម ស្វាយ ចេក ដើមឈើ ផ្កា ត្រី បក្សី ។ល។)

៥. កុមារណាដែលគូសបានល្អជាងគឺជាអ្នកឈ្នះ។

៦. សូមបន្តលេងល្បែងនេះរហូតដល់អស់ពាក្យនៅក្នុងឧទាហរណ៍។

៧. សូមពន្យល់កុមារថា វាពិតជាពិបាកខ្លាំងណាស់ក្នុងការរស់នៅ ប្រសិនបើអ្នកពិការភ្នែក។ ព្រះយេស៊ូវមិនចង់ឲ្យយើងរស់នៅក្នុងស្ថានភាពងងឹតភ្នែក ពិការរូបរាងកាយឬក៏ ប្រលឹងវិញ្ញាណនោះឡើយ។

**៨. ខគម្ពីរចងចាំ**

**កិច្ចការ ១០៖៣៨** *"គឺពីព្រះយេស៊ូវ ពីស្រុកណាសារ៉ែត ដែលព្រះបានចាក់ព្រះវិញ្ញាណ បរិសុទ្ធ និងព្រះចេស្តាឲ្យមកសណ្ឋិតលើទ្រង់ ហើយទ្រង់បានយាងចុះឡើងធ្វើការល្អ ព្រមទាំងប្រោសឲ្យ អស់អ្នក ដែលត្រូវអារក្សសង្កត់សង្កិនបានជាផង ដ្បិតព្រះបានគង់ជាមួយនឹងទ្រង់"*។

**៩. ហត្ថកម្ម**

សូមផាត់ពណ៌ "ព្រះយេស៊ូវប្រោសមនុស្សខ្វាក់ឲ្យជា" ។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
មនុស្សអាចពិការរូបរាងកាយឬក៏ប្រលឹងវិញ្ញាណ។ នៅពេលដែលប្រលឹងវិញ្ញាណរបស់យើងខ្វាក់ យើងនឹងមិនអាចមើលឃើញពីការអស្ចារ្យដែលព្រះបានធ្វើនោះទេ។ ព្រះយេស៊ូវតែងតែធ្វើការនៅក្នុងជីវិត រស់នៅរបស់យើង និងមានព្រះបន្ទូលមកកាន់យើង។ តើវាគួរឲ្យសោកស្តាយប៉ុនណា ប្រសិនបើយើងមិនអាចមើលឃើញពីកិច្ចការដ៏អស្ចារ្យរបស់ព្រះនោះ នេះគឺដោយសារតែយើងបានខ្វាក់ខាងឯប្រលឹងវិញ្ញាណ។ ថ្ងៃនេះសូមឲ្យអ្នកបានអធិស្ឋានទូលសូមទៅ ព្រះឲ្យទ្រង់បានបើកភ្នែកខាងឯព្រលឹងវិញ្ញាណរបស់អ្នក ដើម្បីឲ្យអ្នកអាចមើលឃើញព្រះនិងសេចក្តីស្រលាញ់ របស់ព្រះអង្គដែលមានចំពោះរាស្ត្ររបស់ទ្រង់។

# ព្រះយេស៊ូវប្រោសមនុស្សខ្វាក់ឲ្យជា



សូមសរសេរខគម្ពីរចងចាំ៖______________________________

______________________________

______________________________

______________________________

______________________________